តុលាការខេត្ត
សៀមរាប-ឧត្តរមានជ័យ
<u>សាលក្រម</u>
លេខ ០២ ខ ចុះថ្ងៃទី ២៦
ខែ សីហា ឆ្នាំ ២០០៥
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ១៣៩ ចុះថ្ងៃទី ១១
ខែ មេសា ឆ្នាំ ២០០៥

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## នាមប្រជារាស្ត្រខ្មែរ
## តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥ ដោយមានសមាសភាព :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] ប្រធានតុលាការខេត្ត

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះឈ្មោះ B O A I ភេទប្រុស អាយុ ៦៣ ឆ្នាំ ជនជាតិអ៊ីតាលី កើតនៅក្រុង CAGLIRI សាសនាកាតូលីក ទីលំនៅមុនពេលចាប់ខ្លួន នៅភូមិវត្តបូព៌ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប របររកស៊ីប្រធានក្រុមហ៊ុន CAMIMEX DEVELOPMENT LTD ។ ឪពុកឈ្មោះ A I P O "ស" ម្តាយឈ្មោះ A A A I "ស" ប្រពន្ធឈ្មោះ គ អន មានកូន ០២នាក់ ។ ដោយមានលោក **ស៊ុន សុជាតិ** ជាអ្នកបកប្រែភាសា ។

ឃុំខ្លួនលេខ ៦១៣ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៥ ។

ត្រូវចោទពីបទ **រំលោភលើសេចក្តីទុកចិត្ត** ប្រព្រឹត្តនៅស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

ដើមបណ្តឹងរដ្ឋប្បវេណី លោក ត តន អាយុ ៥០ឆ្នាំ ជនជាតិវៀតណាម របររកស៊ីនាយកក្រុមហ៊ុនអភិវឌ្ឍពាណិជ្ជកម្ម Buuloc ( V.N ) ទីលំនៅនៅភូមិតាបាប់ ឃុំ ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។ ដោយមានលោក ឡេស់ **លីមសុភី** ជាអ្នកបកប្រែភាសា

## <u>ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ</u>

កាលពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៤ ឈ្មោះ B O A I ប្រធានក្រុមហ៊ុន

សាលក្រមនេះចូលជាស្ថាពរនៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៥
ដោយពុំមានគូភាគីណាមួយប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ឡើយ ។
សៀមរាប, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៥
ចៅក្រមជំនុំជំរះ
ហត្ថលេខា និងត្រា
[redacted]

CAMIMEX DEVELOPMENT LTD អ្នកម៉ៅការទូទៅបានចុះកិច្ចសន្យាជាមួយលោក ត តត នាយកក្រុមហ៊ុនសំណង់ពាណិជ្ជ BuuLoc (V.N) ដើម្បីអោយលោក ត តត សាងសង់សណ្ឋាគារ " Angkor Wealth Hotel" នៅខេត្តសៀមរាប ក្នុងតម្លៃសរុប ៥.២៥៥.៦០០ដុល្លារអាមេរិក ដោយក្នុងនោះបានតម្រូវអោយលោក ត តត តម្កល់ប្រាក់ចំនួន ៥០.០០០ដុល្លារអាមេរិកនៅក្នុងគណនីរបស់ឈ្មោះ B O A I ជាមុនសិនហើយប្រាក់តម្កល់ទុក នេះពុំមានភាគីណាមួយអាចដកយកបានឡើយ លុះត្រាតែសំណង់សណ្ឋាគារសាងសង់រួចស្រេច ទើបបង្វិលប្រាក់នេះរោយទៅលោក ត តត វិញ ។

ក្នុងរយៈពេល ១០ថ្ងៃ ប្រសិនបើលោក ត តត ពុំបានបង់ប្រាក់ចូលក្នុងគណនីរបស់លោក B O A I ទេ កិច្ចសន្យាព្រមព្រៀងសាងសង់ត្រូវទុកជាមោឃៈ ប៉ុន្តែនៅក្រោយពេលលោក ត តត បង់ប្រាក់ចូលក្នុងគណនីរបស់លោក B O A I ហើយក្នុងរយៈពេល ១៥ថ្ងៃប្រសិនបើពុំមានការងារឱ្យលោក ត តត ដំណើរការសាងសង់បានទេ លោក B O A I ត្រូវបង្វិលប្រាក់តម្កល់ទុកក្នុងធនាគារអោយទៅលោក ត តត វិញព្រមទាំងត្រូវសងប្រាក់ចំនួន ១០% លើប្រាក់ដែលលោក ត តត បានតម្កល់ទុកក្នុងគណនីរបស់លោក B O A I ។

នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤ B O A I និង លោក ត តត បានព្រមព្រៀងគ្នាចុះកិច្ចសន្យាម្តងទៀត ដោយកែប្រែប្រាក់តម្កល់ក្នុងគណនីរបស់ឈ្មោះ B O A I ត្រឹមតែ ៤៥.០០០ដុល្លារអាមេរិក ហើយលោក ត តត បានបង់ប្រាក់ចំនួន ៤៥.០០០ដុល្លារអាមេរិក ចូលក្នុងគណនីរបស់ឈ្មោះ BENITO ALCIDI លេខ ១០-០១០៩ នៅធនាគារកម្ពុជាសាធារណៈប្រចាំខេត្តសៀមរាប ។

ក្រោយពេលលោក ត តត ដាក់ប្រាក់តម្កល់ក្នុងគណនីរបស់ឈ្មោះ B O A I ឈ្មោះ B O A I ពុំបានផ្តល់ការងារអោយលោក ត តត ដំណើរការងារសាងសង់សណ្ឋាគារតាមកិច្ចសន្យាឡើយ ហើយថែមទាំងបានដកយកប្រាក់ចំនួន ៤៥.០០០ដុល្លារអាមេរិក ដែលលោក ត តត បានតម្កល់ទុកក្នុងធនាគារថែមទៀត ។

ក្នុងរឿងនេះលោក ត តត ជាជនរងគ្រោះ និង ជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណងជាប្រាក់ចំនួន ៤៥.០០០ដុល្លារអាមេរិក និង ទាមទារសំណងជម្ងឺចិត្តចំនួន ១៦.០០០ដុល្លារអាមេរិក ។

**នាពេលសវនាការ**

ជនជាប់ចោទឈ្មោះ B O A I បានឆ្លើយថា ចំពោះអវត្តមានរបស់មេធាវី ខ្លួនសំរេចចិត្តឆ្លើយការពារដោយខ្លួនឯង ។

ថា កាលពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៥ ខ្លួនបានចុះកិច្ចសន្យាផ្តល់ការងារសាងសង់សណ្ឋាគារ"Angkor Wealth Hotel" នៅខេត្តសៀមរាប ក្នុងតម្លៃសរុប ៥.២៥៥.៦០០ដុល្លារអាមេរិក ហើយខ្លួនបានតំរូវអោយលោក ត តត ដាក់ប្រាក់តម្កល់ទុកក្នុងគណនីខ្លួនលេខ ១០-០១០៩ ក្នុងធនាគារកម្ពុជាសាធារណៈ ។

នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤ ខ្លួន និង លោក ត តត បានចុះកិច្ចសន្យាសាងសង់សណ្ឋាគារ " Angkor Wealth Hotel" តែសុំកែតម្រូវប្រាក់តម្កល់ទុកក្នុងគណនីរបស់ខ្លួនត្រឹមតែ ៤៥.០០០ដុល្លារអាមេរិកប៉ុណ្ណោះ ហើយលោក ត តត បានបង្វិលសាច់ប្រាក់សុទ្ធចំនួន ៤៥.០០០ដុល្លារអាមេរិក ចូលទៅក្នុងគណនីរបស់ខ្លួន ក្នុងពេលនោះតែម្តង ។

ក្រោយពេលលោក ត តត ដាក់ប្រាក់តម្កល់ក្នុងគណនីរបស់ខ្លួនរួចហើយ លោក ត នម ជាម្ចាស់សណ្ឋាគារមិនព្រមផ្តល់ការងារឱ្យខ្លួន ទើបខ្លួនពុំបានផ្តល់ការងារសាងសង់សណ្ឋាគារឱ្យទៅលោក ត តត ដែរ ។

ថា ប្រាក់ដែលលោក ត តត បានដាក់តម្កល់ទុកក្នុងគណនីរបស់ខ្លួននោះ ខ្លួនបានយកទៅអោយលោក

គ នម ខ្ចីអស់ចំនួន ៤០.០០០ដុល្លាអាមេរិកអោយទៅឈ្មោះ ឆ ទច ខ្ចីអស់ចំនួន ២០.០០០ដុល្លាអាមេរិក និង អោយឈ្មោះ ៣ សផ ខ្ចីអស់ចំនួន ១២.០០០ដុល្លាអាមេរិកទៀត ។

ក្នុងរឿងនេះខ្លួនសុំសងប្រាក់ទៅលោក ត តត ចំនួន ៦១.០០០ដុល្លាអាមេរិក ដោយក្នុងនោះខ្លួនសុំសង រំលោះក្នុងមួយខែចំនួន ២.០០០ដុល្លារអាមេរិក គឺក្នុងនោះខ្លួនសងក្នុងមួយខែចំនួន ១.០០០ដុល្លាអាមេរិក និះ ប្អូន ខ្លួនធានាសងជំនួសខ្លួនក្នុងមួយខែចំនួន ១.០០០ដុល្លាអាមេរិកដែរ ។

ដើមបណ្តឹងរដ្ឋប្បវេណីលោក ត តត បានឆ្លើយថា ខ្លួនជានាយកក្រុមហ៊ុនសំណង់ពាណិជ្ជ Buulec (V.N) ។ នៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៤ ខ្លួនបានចុះកិច្ចសន្យាជាមួយលោក B O A I ជាប្រធានក្រុមហ៊ុន CAMIMEX DEVELOPMENT LTD ដើម្បីសាងសង់សណ្ឋាគារផ្កាយ ៥ នៅខេត្តសៀមរាប មានទឹកប្រាក់ចំនួន ៥.២៥៥.៦០០ដុល្លាអាមេរិក ។

នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤ ខ្លួនបានបង្វិលប្រាក់របស់ខ្លួនចំនួន ៤៥.០០០ដុល្លាអាមេរិកបញ្ចូល ទៅក្នុងគណនីរបស់លោក B O A I នៅធនាគារកម្ពុជាសាធារណៈប្រចាំខេត្តសៀមរាប ។

ក្រោយពេលខ្លួនបញ្ចូលប្រាក់ក្នុងគណនីរបស់លោក B O A I ហើយលោក B O A I បានសន្យានឹង បញ្ជាអោយបើកការដ្ឋានសាងសង់ តែប្រសិនបើគាត់ពុំគោរពតាមកិច្ចសន្យាទេ គាត់សន្យាសងប្រាក់អោយខ្លួនវិញ និង បង់ប្រាក់ពិន័យអោយខ្លួនចំនួន ១០% ក្នុងមួយខែលើប្រាក់ដែលខ្លួនបានដាក់តម្កល់ទុកនោះ ។

ថា ក្រោយពេលខ្លួនបញ្ជូនទឹកប្រាក់ចំនួន ៤៥.០០០ដុល្លាអាមេរិក ទៅក្នុងគណនីរបស់លោក B O A I លោក B O A I ពុំបានគោរពតាមកិច្ចសន្យាដែលបានព្រមព្រៀងគ្នាឡើយ ហើយនៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៤ លោក B O A I បានចុះកិច្ចសន្យាព្រមបង្វិលសាច់ប្រាក់សងអោយខ្លួនវិញ និង បង់ប្រាក់ពិន័យអោយខ្លួនចំនួន ១៨.០០០ដុល្លាអាមេរិក គឺសុំសងនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៤ ចំនួន ៣.០០០ដុល្លាអាមេរិក និង នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ចំនួន ៦០.០០០ដុល្លារអាមេរិកទៀត ។

ថា រហូតមកទល់ពេលនេះលោក B O A I មិនព្រមសងខ្លួនតាមកិច្ចសន្យាឡើយ ។

ក្នុងរឿងនេះខ្លួនយល់ព្រមទទួលយកសំណងពីឈ្មោះ B O A I ចំនួន ៦១.០០០ដុល្លាអាមេរិក គឺអនុញ្ញាត អោយសងរំលោះក្នុងមួយខែចំនួន ២.០០០ដុល្លាអាមេរិក និង សំណូមពរសុំឱ្យតុលាការដោះលែងឈ្មោះ B O A I អោយមានសេរីភាពឡើងវិញ ។

លោក V O A I ជាប្អូនបង្កើតរបស់ឈ្មោះ B O A I ជាអ្នកធានាបានឆ្លើយថា ចំនួនប្រាក់ដែលបង ខ្លួនត្រូវសងទៅលោក ត តត ក្នុងមួយខែចំនួន ២.០០០ដុល្លាអាមេរិកនោះខ្លួនធានាជួយសងក្នុងមួយខែចំនួន ១.០០០ដុល្លាអាមេរិក និង បងរបស់ខ្លួនចេញសងចំនួន ១.០០០ដុល្លាអាមេរិកដែរ ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ ៣ សផ បានឆ្លើយថា កាលពីឆ្នាំ ២០០៣ ខ្លួនបានជួបឈ្មោះ គ អន នៅផ្សារធំថ្មី ហើយឈ្មោះ គ អន ប្រាប់ថា ប្តីរបស់គាត់ឈ្មោះ B O ប្រកបរបរធ្វើសំណង់នៅខេត្តសៀមរាប ។ នៅក្នុង ខែមីនា ឆ្នាំ ២០០៤ ទើបខ្លួនបានជួបឈ្មោះ B O ហើយខ្លួនបានសុំមើលប្លង់សាងសង់សណ្ឋាគារពីលោក B O យក ទៅប្រគល់អោយឯកឧត្តម ឃ មឌ ហើយឯកឧត្តម ឃ មឌ បានឱ្យយោបល់មកខ្លួនថា ចាំគាត់អោយក្រុមហ៊ុន របស់លោក ត តត ជួបជាមួយលោក B O A I ។ ក្រោយមកក្រុមហ៊ុនរបស់លោក ត តត និង លោក B O A I បានឯកភាពគ្នាចុះកិច្ចសន្យាសាងសង់នៅខេត្តសៀមរាប ដែលមានទឹកប្រាក់សរុប ៥.០០០.០០០ដុល្លាអាមេរិក និង បានព្រមព្រៀងគ្នាអោយលោក ត តត ដាក់ប្រាក់តម្កល់ទុកក្នុងគណនីរបស់លោក B O A I ចំនួន ៤៥.០០០ ដុល្លាអាមេរិក ។ ថាពេលគេចុះកិច្ចសន្យាសាងសង់ ខ្ញុំ និង ឯកឧត្តម ឃ មឌ បានចុះហត្ថលេខាធ្វើជាសាក្សី ។ ថា

រឿង គេដាក់ប្រាក់តម្កល់យ៉ាងដូចម្តេចខ្លួនមិនបានដឹងទេ ហើយក៏វិរដើងសារខ្លួន ពុំទាន់បានទទួលនៅឡើយដែរ ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ ឃ សទ បានឆ្លើយថា លោក B O A I បានចុះកិច្ចសន្យាជាមួយលោក ត តត ដោយសន្យាផ្តល់ការងារសាងសង់សណ្ឋាគារថ្នាក់ផ្កាយ៥ នៅខេត្តសៀមរាប ឱ្យលោក ត តត សាងសង់ ហើយតម្រូវអោយលោក ត តត យកប្រាក់ចំនួន ៤៥.០០០ដុល្លាអាមេរិក ទៅតម្កល់ទុកក្នុងគណនីរបស់លោក B O A I ជាមុនសិន ទើបអនុញ្ញាតអោយបើកការដ្ឋានសាងសង់នៅក្នុងរយៈពេល ១៥ថ្ងៃក្រោយ ។ ថាលោក ត តត បានយកប្រាក់ចំនួន ៤៥.០០០ដុល្លាអាមេរិក ទៅដាក់តម្កល់នៅក្នុងធនាគារកម្ពុជាសាធារណៈខេត្តសៀមរាប ក្នុងគណនីរបស់លោក B O A I តែរហូតមកទល់ពេលនេះលោក B O A I ពុំមានការដ្ឋានសណ្ឋាគារអោយ លោក ត តត សាងសង់តាមកិច្ចសន្យា និង បានដកយកសាច់ប្រាក់ចាយអស់ថែមទៀត ។

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា

មានពិរុទ្ធភាពធ្ងន់ធ្ងរលើឈ្មោះ B O A I ពីបទរំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤ ។

ហេតុនេះសូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ២៤៣៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៤ របស់ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញទុកជាបានការតាមច្បាប់ពេញទាំងមូល ។

សូមតុលាការផ្តន្ទាទោសជនជាប់ចោទតាមបញ្ញត្តិមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

ជនជាប់ចោទឈ្មោះ B O A I បាននិយាយសំដីចុងក្រោយបង្អស់ថា សូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-បានស្តាប់ចម្លើយជនជាប់ចោទ
-បានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
-បានស្តាប់ចម្លើយសាក្សី
-បានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ
-បានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

## តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-កាលពីថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤ ឈ្មោះ B O A I ប្រធានក្រុមហ៊ុន CAMIMEX DEVE OPMENT LTD បានចុះកិច្ចសន្យាជាមួយលោក ត តត នាយកក្រុមហ៊ុនសំណង់ពាណិជ្ជ ដោយសន្យានឹងប្រគល់ការងារសាងសង់សណ្ឋាគារថ្នាក់ផ្កាយ៥ នៅខេត្តសៀមរាបពីម្ចាស់សណ្ឋាគារលោក ត នម ទាំងស្រុងអោយទៅលោក ត តត សាងសង់បន្ត ។ ប៉ុន្តែតំរូវឱ្យលោក ត តត យកប្រាក់ចំនួន ៤៥.០០០ដុល្លាអាមេរិកដាក់តម្កល់ក្នុងធនាគារកម្ពុជាសាធារណៈខេត្តសៀមរាប ក្នុងគណនីរបស់ខ្លួនជាមុនសិន ។ នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤ លោក ត តត បានយកសាច់ប្រាក់ចំនួន

៤៥.០០០ដុល្លាអាមេរិកដាក់តម្កល់ក្នុងគណនីរបស់ឈ្មោះ B O A I ក្នុងធនាគារកម្ពុជាសាធារណៈ ខេត្តសៀមរាប ។

-ក្នុងកិច្ចសន្យាបានកំណត់ថា ក្នុងរយៈពេល ១៥ថ្ងៃបើភាគីឈ្មោះ B O A I មិនបានប្រគល់ការដ្ឋានឱ្យភាគីលោក ត តត បានដំណើរការសាងសង់ទេ ត្រូវបង្វិលសាច់ប្រាក់ចំនួន ៤៥.០០០ដុល្លាអាមេរិកទៅលោក ត តត វិញ និង បង់ប្រាក់ពិន័យបន្ថែម ១០%នៃទឹកប្រាក់ដែលបានដាក់តម្កល់នោះថែមទៀត ។

-បន្ទាប់ពីបានទទួលប្រាក់នៅក្នុងគណនីរបស់ខ្លួនហើយ ឈ្មោះ B O A I បានដកយកសាច់ប្រាក់នោះចាយវាយអស់ហើយគេចខ្លួនបាត់ ដោយពុំបានផ្តល់ការងារអោយលោក ត តត តាមកិច្ចសន្យាទេ ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទមានចែង និង ផ្តន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

-ដើមបណ្តឹងរដ្ឋប្បវេណីលោក ត តត ប្តឹងទាមទារសំណងជាប្រាក់ចំនួន ៦១.០០០ដុល្លាអាមេរិក គឺ ប្រាក់ដើមចំនួន ៤៥.០០០ដុល្លាអាមេរិក និង ប្រាក់ជម្ងឺចិត្តចំនួន ១៦.០០០ដុល្លាអាមេរិក តែយល់ព្រមអោយសងរំលោះក្នុងមួយខែចំនួន ២.០០០ដុល្លាអាមេរិក ដោយមានអ្នកធានាលោក V O A I ជួយចេញសងក្នុងមួយខែ ១.០០០ដុល្លាអាមេរិក ហើយសំណូមពរសុំឱ្យតុលាការដោះលែងឈ្មោះ B O A I អោយមានសេរីភាព ដើម្បីមានលទ្ធភាពអាចរកប្រាក់សងខ្លួនវិញ នោះតុលាការនឹងពិចារណាចំណុចនេះតាមច្បាប់ ។

-ជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកទីមួយ ហើយដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យជនជាប់ចោទនៅក្រៅឃុំ ដើម្បីមានលទ្ធភាពរកប្រាក់សងខ្លួនវិញ ។

-មាត្រា ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ មានចែងអំពីការព្យួរទោស ដើម្បីទុកលទ្ធភាពអោយអ្នកជាប់ទោសកែប្រែខ្លួន ។

## ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោសឈ្មោះ B O A I ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ ( មួយឆ្នាំ) តែទោសនេះត្រូវព្យួរថិរវេលាសាកល្បងកំណត់ ០៥ឆ្នាំ ។

ពីបទ **រំលោភលើសេចក្តីទុកចិត្ត** តាមបញ្ញត្តិមាត្រា ៤៦ និង មាត្រា ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ប្រព្រឹត្តនៅស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤ ។

២-សំរេចឱ្យឈ្មោះ B O A I សងសំណងជាប្រាក់ចំនួន ៦១.០០០ដុល្លាអាមេរិក ( ប្រាំមួយម៉ឺនមួយពាន់ដុល្លាអាមេរិក) ទៅលោក ត តត ។ ប៉ុន្តែប្រាក់នេះសំរេចឱ្យឈ្មោះ B O A I សងរំលោះក្នុងមួយខែចំនួន ១.០០០ដុល្លាអាមេរិក ( មួយពាន់ដុល្លាអាមេរិក) និង ឱ្យអ្នកធានាឈ្មោះ V O A I សងរំលោះក្នុងមួយខែចំនួន ១.០០០ដុល្លាអាមេរិក ( មួយពាន់ដុល្លាអាមេរិក) សរុបទាំងអស់ ២.០០០ដុល្លាអាមេរិក (ពីរពាន់ដុល្លាអាមេរិក) ដោយកំណត់សងនៅរៀងរាល់ថ្ងៃទី ២០ ចាប់ពីខែ កញ្ញា ឆ្នាំ ២០០៥ រហូតដល់អស់ទឹកប្រាក់ចំនួន ៦១.០០០ដុល្លាអាមេរិក ( ប្រាំមួយម៉ឺនមួយពាន់ដុល្លាអាមេរិក ) ។

ក្នុងករណីគ្មានប្រាក់ធនទទួលសងអនុវត្តតាមមាត្រា ៧ ច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយ គឺចំនួន ០២ ឆ្នាំ ។

៣-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខតួភាគីបើកផ្លូវឧទ្ធរណ៍កំណត់ ០២ខែគិតពីថ្ងៃនេះតទៅ ។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខា និង ត្រា
[redacted]

ចៅក្រមជំនុំជំរះ
ហត្ថលេខា និង ត្រា
[redacted]